**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីអំពាវនាវ

អនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីសម្ព័ន្ធមេត្រីភាពរវាងកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន អង្គភាពស៊ីវិល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួង ក៏ដូចជាភ្នាក់ងារជ្រើសរើសឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរឹតចំណងសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចអន្តរាគមន៍លេខ៧ ដែលកំពុងឈរជើងការពារតាមតំបន់ព្រំដែនខេត្តព្រះវិហារ ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនេះ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** នឹងដឹកនាំប្រតិភូចុះសួរសុខទុក្ខ និងរៀបចំពិធីសំណេះសំណាល ជាមួយបងប្អូន និងគ្រួសារយុទ្ធជន **នៅថ្ងៃចន្ទ ៧រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៨:៣០នាទីព្រឹក** នៅទីបញ្ជាការកងពល ស្ថិតក្នុងភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ក្នុងស្មារតីនេះ ក្រសួងសូមអំពាវនាវដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ មេត្តាជួយឧបត្ថម្ភនូវ ថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគនានាតាមសទ្ធាជ្រះថ្លា ដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ស្មារតីក្លាហានស្នេហាជាតិរបស់បងប្អូនកងទ័ពយើង។

ក្រសួងសង្ឃឹមជឿជាក់ថា **ឯកឧត្តម លោកជំទាវ លោក លោកស្រី** នឹងចូលរួមគាំទ្រសកម្មភាពនេះ ដើម្បីរួមចំណែកជាមួយកងពលខាងលើឱ្យបានច្រើនកុះករ។

បញ្ជាក់៖ - រសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ ចេញដំណើរដោយមធ្យោបាយផ្ទាល់ខ្លួន
- ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៧:៣០នាទីព្រឹក ជួបជុំគ្នានៅទីប្រជុំជនឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ថ្ងៃ សុក្រ ៥កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៨


សូមទំនាក់ទំនងខុទ្ទកាល័យ
-លោក ទៀវ ម៉ាក់តែល ០១២ ៨២៣ ៣៧៥
-លោក អ៊ួច ពិសី ០១៦ ៩០២ ៩០៤
-លោកស្រី ជា សុខេន ០៧៧ ៧០០ ៧២៦